**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៥២ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការដាក់ឱ្យប្រើថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២១/៥៦៤ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមឌីជីថល
- បានឃើញអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍និងជាប្រធានគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល

## សម្រេច

**មាត្រា១ .-**

ត្រូវបានដាក់ឱ្យប្រើថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh របស់រាជរដ្ឋាភិបាល ដែលអភិវឌ្ឍដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្នុងគោលបំណងលុបបំបាត់ការក្លែងបន្លំឯកសារ ផ្តល់ភាពងាយស្រួលក្នុងការប្រើប្រាស់និងផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃឯកសារ ផ្តល់ទំនុកចិត្ត ចំណេញពេលវេលា និងកាត់បន្ថយការចំណាយនានា ព្រមទាំងជំរុញការធ្វើបរិវត្តកម្មឌីជីថលសេវាសាធារណៈ។

**មាត្រា២ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១-ថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh សំដៅដល់ថ្នាលបច្ចេកវិទ្យារបស់រាជរដ្ឋាភិបាល ដែលអភិវឌ្ឍដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សម្រាប់ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃឯកសារ ដែលមានដាក់បញ្ចូល យូ.អ.កូដ ស្តង់ដា។

២-យូ.អ.កូដ ស្តង់ដា សំដៅដល់ យូ.អ.កូដ ដែលអភិវឌ្ឍដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដោយប្រើបច្ចេកវិទ្យាប្លុកឆេន និងគោរពតាមគោលការណ៍បូរណភាព យថាភូតភាព និងសុពលភាព។

៣-បច្ចេកវិទ្យាប្លុកឆេន សំដៅដល់សំណុំប្រតិបត្តិការជាប្លុក តភ្ជាប់គ្នាពីមួយទៅមួយដោយសុវត្ថិភាព តាមរយៈការប្រើលេខសម្គាល់សម្ងាត់និងកំណត់ត្រាពេលវេលានៃប្រតិបត្តិការដែលមិនអាចកែបាន និងត្រូវបានចែករំលែកនៅក្នុងបណ្តាញពាក់ព័ន្ធ។

**មាត្រា៣ .-**

ការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃឯកសារ ត្រូវធ្វើឡើងតាមរយៈការដាក់បញ្ចូល យូ.អ.កូដ ស្តង់ដា នៅលើឯកសារដែលអាចផ្ទៀងផ្ទាត់បានតាមថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh។

យូ.អ.កូដ ស្តង់ដា ដែលត្រូវបានអភិវឌ្ឍដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដោយប្រើបច្ចេកវិទ្យាប្លុកឆេន ត្រូវគោរពតាមគោលការណ៍យថាភូតភាព បូរណភាព និងសុពលភាព។

**មាត្រា៤ .-**

ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងនីតិបុគ្គលសាធារណៈ ត្រូវធ្វើផែនការដាក់បញ្ចូល យូ.អ.កូដ ស្តង់ដា ដែលអាចផ្ទៀងផ្ទាត់បានតាមថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh លើឯកសាររបស់ខ្លួន។

នីតិបុគ្គលឯកជន ដែលមានបំណងដាក់បញ្ចូល យូ.អ.កូដ ស្តង់ដា ដែលអាចផ្ទៀងផ្ទាត់បានតាមថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh លើឯកសាររបស់ខ្លួន អាចធ្វើការស្នើសុំមកក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ទទួលសំណើសុំដាក់បញ្ចូល យូ.អ.កូដ ស្តង់ដា តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ដោយសំណើនោះត្រូវផ្តល់ព័ត៌មានដូចខាងក្រោម៖

- ឈ្មោះឯកសារដែលត្រូវប្រើ យូ.អ.កូដ ស្តង់ដា
- គំរូរបស់ឯកសារ
- ចំនួនឯកសារដែលត្រូវប្រើ យូ.អ.កូដ ស្តង់ដា
- ឈ្មោះនិងលេខទំនាក់ទំនងរបស់ជនបង្គោលដែលទទួលបន្ទុកការងារ។

ក្នុងករណីក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងនីតិបុគ្គលសាធារណៈដែលកំពុងប្រើ យូ.អ.កូដ នៅលើឯកសាររបស់ខ្លួន អាចរៀបចំផែនការផ្ទេរការប្រើ យូ.អ.កូដ ដែលមានស្រាប់មកប្រើ យូ.អ.កូដ ស្តង់ដា ដែលអាចផ្ទៀងផ្ទាត់បានតាមថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh តាមការសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៥ .-**

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវរៀបចំផែនការដាក់បញ្ចូល យូ.អ.កូដ ស្តង់ដា នៅលើឯកសារតាមការស្នើសុំរបស់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ នីតិបុគ្គលសាធារណៈ និងនីតិបុគ្គលឯកជន ឱ្យបានរួចរាល់តាមផែនការដែលបានព្រមព្រៀង ក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីទទួលបានព័ត៌មានគ្រប់គ្រាន់ដូចមានចែងក្នុងមាត្រា៤នៃអនុក្រឹត្យនេះ។

ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ នីតិបុគ្គលសាធារណៈ និងនីតិបុគ្គលឯកជន ដែលទទួលបានឯកសារដែលដាក់បញ្ចូល យូ.អ.កូដ ស្តង់ដា ពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ អាចប្រើតាមតម្រូវការចាំបាច់របស់ស្ថាប័នរៀងៗខ្លួន។

**មាត្រា៦ .-**

ការប្រើឯកសារដែលមានដាក់បញ្ចូល យូ.អ.កូដ ស្តង់ដា អាចផ្ទៀងផ្ទាត់បានតាមរយៈថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh មិនតម្រូវឱ្យមានការធ្វើនីត្យានុកូលកម្មលើឯកសារថតចម្លងក្នុងទម្រង់ជាក្រដាសឡើយ។

**មាត្រា៧ .-**

ការផ្ទៀងផ្ទាត់ឯកសារដែលដាក់បញ្ចូល យូ.អ.កូដ ស្តង់ដា លើថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh មិនតម្រូវឱ្យមានការបង់កម្រៃឡើយ។

ការបង់កម្រៃសេវាលើការស្នើសុំដាក់បញ្ចូល ឃ្យូ.អ.កូដ ស្តង់ដា លើឯកសារដោយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ នីតិបុគ្គលសាធារណៈ និងនីតិបុគ្គលឯកជន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា៨ .-**

ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ នីតិបុគ្គលសាធារណៈ និងនីតិបុគ្គលឯកជន ដែលទទួលបានឯកសារដែលដាក់បញ្ចូល ឃ្យូ.អ.កូដ ស្តង់ដា មានសិទ្ធិរក្សាទុកឯកសារក្នុងប្រព័ន្ធទិន្នន័យរបស់ខ្លួន ឬរបស់មជ្ឈមណ្ឌលទិន្នន័យរបស់ប្រតិបត្តិករដែលទទួលបានអាជ្ញាបណ្ណពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ឬស្នើសុំឱ្យក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រក្សាទុកក្នុងមជ្ឈមណ្ឌលទិន្នន័យជាតិ។

**មាត្រា៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១២កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែមីនា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**និងជាប្រធានគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល**

**ជា វ៉ាន់ដេត**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ